DFID Department for International Development

# គោលការណ៍ណែនាំ
# ពីការអនុវត្តឱ្យមានប្រសិទ្ធភាពដល់
# ក្រុមអ្នកគ្រប់គ្រង និងប្រើប្រាស់ធនធានជលផលក្នុងមូលដ្ឋាន









# មាតិកា

ម.ព.ឯ.ក AIDOC
Code: 147-032
Date:
Donated by:

**សេចក្ដីផ្ដើម** ........................................ 2

**គោលបំណង** ........................................ 2

-តើអ្វីទៅជាប្រព័ន្ធទឹកនៅតាមជនបទ ?........................................ 3

-តើធនធានវារីសត្វនៅតាមជនបទមានអ្វីខ្លះ ?........................................ 3

-តើក្រុមអ្នកគ្រប់គ្រង និងប្រើប្រាស់ធនធានជលផលក្នុងមូលដ្ឋាន គឺជាអ្នកណា ? ........................ 4

-មូលហេតុដែលនាំឱ្យមានគំនិតរៀបចំបង្កើតក្រុមអ្នកគ្រប់គ្រង និងប្រើប្រាស់ធនធានជលផលក្នុងមូលដ្ឋាន......5

-តើត្រូវបង្កើតក្រុមការងារនេះយ៉ាងដូចម្ដេច?........................................ 6

-សកម្មភាពខ្លះៗ នៃការគ្រប់គ្រងប្រព័ន្ធទឹកដោយកសិករ........................................ 7

-ការរៀបចំ និងការអនុវត្តផែនការសកម្មភាព........................................ 8

-តើស្ថានភាពនៃធនធានជលផលអាចវាយតំលៃបានយ៉ាងដូចម្ដេច?........................................ 9

-តើខ្ញុំត្រូវធ្វើដូចម្ដេចដើម្បីដឹងថា ការងារក្រុមអ្នកគ្រប់គ្រង និងប្រើប្រាស់ធនធានជលផលក្នុងមូលដ្ឋានមានប្រសិទ្ធភាព ?... 10

-ខ្ញុំឆ្ងល់ថា តើហេតុអ្វីបានជាចាប់អារម្មណ៍ទៅលើក្រុមអ្នកគ្រប់គ្រង និងប្រើប្រាស់ធនធានជលផល ?......... 11

-គំរូនៃរបៀបវារៈ សំរាប់ការរៀបចំការប្រជុំទៀងទាត់ ........................................ 12

-ការផ្ទៀងផ្ទាត់សកម្មភាពការងារ សំរាប់ការត្រួតពិនិត្យក្រុមអ្នកគ្រប់គ្រង និងប្រើប្រាស់ធនធានជលផលក្នុងមូលដ្ឋាន ?... 12

## សេចក្តីផ្តើម

**វារីសត្វ** គឺជាធនធានជលផលមានសារៈប្រយោជន៍បំផុតនៅតាមជនបទ ដែលមិនអាចខ្វះបានសម្រាប់ប្រជាពលរដ្ឋកម្ពុជា ពិសេសប្រជាកសិករដែលកំពុងរស់នៅតាមស្រុកស្រែចំការ តែងតែពឹងផ្អែកលើធនធានជលផលសម្រាប់ការចិញ្ចឹមជីវិតក្នុងជីវភាពគ្រួសារប្រចាំថ្ងៃ។ ធនធានជលផលបាន និងកំពុងជួយវិភាគទានដល់ការរកប្រាក់ចំណូលសំខាន់គឺបានជួយដល់ការប្រើប្រាស់ម្ហូបអាហាររបស់ប្រជាពលរដ្ឋកម្ពុជា។ ជាទូទៅ នៅតាមជនបទធនធានជលផល ត្រូវបានគេរកឃើញ ភាគច្រើនមាននៅតាមតំបន់ទំនាបក្នុងភូមិ។ សកម្មភាពនៃវារីសត្វនៅតាមតំបន់ទំនាបមានភាពសកម្មបំផុត ពិសេសគឺត្រីដែលបានធ្វើបំលាស់ទីពីកន្លែងមួយ ទៅកន្លែងមួយទៀត ដូចជា បំលាស់ទីទៅវាលស្រែ ឆ្លងកាត់ស្នាមភ្លោះ ចូលប្រឡាយ ទៅស្រះ និងចូលទៅកន្លែងផ្សេងទៀត ដែលនៅជិតតំបន់ទឹកធម្មជាតិនានា ដើម្បីធ្វើការពង កូន និងលូតលាស់នៅទីនោះ។ បើយើងគ្រប់គ្រងប្រព័ន្ធទឹកទាំងនេះបានល្អ ពិសេសប្រព័ន្ធទឹកណាដែលមិនរីងស្ងួតនៅរដូវប្រាំងនោះ នឹងធ្វើឱ្យផលត្រីមានការកើនឡើងជាលំដាប់។ ដូចនេះការបង្កើតក្រុមអ្នកគ្រប់គ្រង និងប្រើប្រាស់ធនធានជលផលក្នុងមូលដ្ឋាន គឺជាការត្រឹមត្រូវ និងចាំបាច់បំផុតដើម្បីធានាបាននូវការរក្សា និងបង្កើនផលស្តុកធម្មជាតិ ព្រមទាំងការប្រើប្រាស់ធនធានជលផលក្នុងមូលដ្ឋាន ឱ្យមាននិរន្តរភាព។

នាយកដ្ឋានជលផលបានសហការជាមួយគម្រោង AIT- SRS (Self Recruiting Species) (ការនេសាទវារីសត្វឱ្យមាននិរន្តរភាព) ធ្វើការសិក្សាស្រាវជ្រាវរយៈពេល ៣ឆ្នាំ កន្លងមក (២០០១-២០០៤) នៅតាមជនបទ ក្នុងខេត្តស្វាយរៀង និងខេត្តតាកែវ អំពីយុទ្ធសាស្ត្រនៃការគ្រប់គ្រង និងការប្រើប្រាស់ផលត្រីធម្មជាតិរបស់ប្រជាកសិករឱ្យមាននិរន្តរភាព ។ ទីតាំងសិក្សារបស់គម្រោង គឺនៅតំបន់ខ្ពស់ក្នុងខេត្តតាកែវ និងតំបន់ទំនាបក្នុងខេត្តស្វាយរៀង ដែលស្ថិតនៅក្នុងតំបន់ **គ្មានដែនឡូត៍នេសាទ និងក្នុងដែនទឹកធម្មជាតិដទៃទៀតដែលនៅឆ្ងាយពីដែនឡូត៍នេសាទ** ។ លទ្ធផលនៃការសិក្សាក្នុងតំបន់គោលដៅរបស់គម្រោង បានបង្ហាញពីការរកឃើញយុទ្ធសាស្ត្រគ្រប់គ្រងផលត្រីធម្មជាតិរបស់ប្រជាកសិករក្នុងមូលដ្ឋាន ប្រកបដោយប្រសិទ្ធភាព ។ នាយកដ្ឋានជលផលបានរៀបចំបោះពុម្ពឯកសារដែលបានមកពីលទ្ធផលនៃការសិក្សានេះ ក្នុងគោលបំណងដូចខាងក្រោម :-

## គោលបំណង

ដើម្បីគ្រប់គ្រងធនធានជលផលនៅតាមជនបទ ដែលគ្មានដែនឡូត៍នេសាទឱ្យបានល្អប្រសើរ ឆ្លើយតបទៅនឹងតម្រូវការចាំបាច់នូវការប្រើប្រាស់ផលវារីសត្វរបស់ប្រជាកសិករឱ្យមានស្ថេរភាព និងនិរន្តរភាព ក្នុងគោលបំណងផ្សព្វផ្សាយចំណេះដឹងជាមូលដ្ឋានដល់កសិករគ្រប់តំបន់ទាំងអស់ ដើម្បីយល់ជ្រួតជ្រាប និងជួយផ្សព្វផ្សាយបន្តទៅកសិករតំបន់ដទៃទៀត ពីរបៀបគ្រប់គ្រងរួមគ្នានូវប្រព័ន្ធទឹកផ្សេងៗដែលជាកម្មសិទ្ធផ្ទាល់របស់កសិករ ដើម្បីជាផលប្រយោជន៍រួមសម្រាប់បង្កើនផលត្រីក្នុងប្រព័ន្ធទឹកគ្រប់គ្រងរបស់ខ្លួនផង និងជាប្រយោជន៍ដល់កសិករផ្សេងៗទៀត ដែលគ្មានប្រព័ន្ធទឹកសម្រាប់ចាប់ត្រីទទួលទានប្រចាំថ្ងៃ និងអាចរកប្រាក់ចំណូលពីការងារគ្រប់គ្រងប្រព័ន្ធទឹកទាំងនេះផង ។


តើអ្វីទៅជាប្រព័ន្ធទឹក
នៅតាមជនបទ ?
វាលលិចទឹក
ស្រែ
ត្រពាំង
ប្រឡាយ


តើធនធានវារីសត្វនៅតាម
ជនបទមានអ្វីខ្លះ ?

## តើក្រុមអ្នកគ្រប់គ្រង និងប្រើប្រាស់ធនធានជលផល ក្នុងមូលដ្ឋាន គឺជាអ្នកណា ?

ជាគ្រួសារកសិករភាគច្រើន ដែលចូលរួមធ្វើការងារស្រុះគ្នា ក្នុងការងារគ្រប់គ្រងប្រព័ន្ធទឹក (រួមមាន ស្រះ បឿ វាលស្រែ ថ្នក ត្រពាំង ...) ណាមួយ ក្នុងសហគមន៍ ដើម្បីបង្កើនធនធានជលផលក្នុងមូលដ្ឋាន ។





ធនធានជលផលក្នុងមូលដ្ឋានត្រូវបានប្រើប្រាស់ ដោយកសិករដែលបានមកពីវាលស្រែរបស់ខ្លួន វាលស្រែអ្នកជិតខាង និងពីតំបន់ទឹកធម្មជាតិនានា។ ក្រុមអ្នកគ្រប់គ្រង និងប្រើប្រាស់ធនធានជលផលក្នុងមូលដ្ឋាន អាចជួយសមាជិករបស់ខ្លួន កំណត់រកការតភ្ជាប់គ្នាពីប្រព័ន្ធទឹកនីមួយៗ ដើម្បីឱ្យចាប់បានផលត្រីដូចគ្នា ស្វែងរកវិធីគ្រប់គ្រងរួមគ្នា ហើយក៏ជួយ :

- លើកទឹកចិត្តដល់ប្រជាពលរដ្ឋក្នុងភូមិ ឱ្យគាត់បានចូលរួមស្តាប់ចែករំលែកចំណេះដឹង និងបទពិសោធន៍ពីគ្នាទៅវិញទៅមក ។
- ជំរុញឱ្យគាត់មានការចូលរួមឱ្យបានច្រើនក្នុងចំណោមគ្រួសារកសិករ ក្នុងការធ្វើសេចក្តីសម្រេចចិត្ត ដើម្បីកែលំអការគ្រប់គ្រងធនធានជលផលឱ្យបានល្អប្រសើរ ។
- គាំទ្រប្រជាពលរដ្ឋក្នុងភូមិ និងនៅក្នុងសហគមន៍ឱ្យមានភាពទទួលខុសត្រូវខ្ពស់ក្នុងការងារគ្រប់គ្រង ។

តំបន់អ្នកគ្រប់គ្រង និងប្រើប្រាស់ធនធានជលផល ក្នុងភូមិស្វាយចេក ឃុំស្វាយចេក ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង



# មូលហេតុដែលនាំឱ្យមានគំនិត
# រៀបចំបង្កើតក្រុមអ្នកគ្រប់គ្រង និងប្រើប្រាស់ធនធានជលផលក្នុងមូលដ្ឋាន

តំបន់ខ្លះ នៅតាមវាលស្រែ ថ្លុក ត្រពាំង ឬស្រះធម្មជាតិនានា បានរីងរាក់នៅរដូវប្រាំង ហើយផលត្រីដែលចាប់បាន មានការថយចុះជាលំដាប់ ពីមួយឆ្នាំ ទៅមួយឆ្នាំ ។





ការធ្វើនេសាទខុសច្បាប់ ដោយប្រើអាគុយឆក់ ស្បៃមុង ថ្នាំបំពុល ឬ បូមបាចពង្រីងចាប់ត្រីទាំងអស់ ..។ល ។

ចំនួនអ្នកនេសាទបានកើនឡើងជារៀងរាល់ឆ្នាំ ។

ផលនេសាទទាំងនេះ មិនអាចបំពេញបានតាមសេចក្តីត្រូវការរបស់ប្រជាកសិករប្រើប្រាស់ប្រចាំថ្ងៃទេ ។



